ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Inform-អជក-14-08-14 ធា-បណ-P 82

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ៧៧៣៧ អជក.អក.ធប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជាសូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ២៣ រូប ដើម្បីចូលបម្រើការងារនៅអង្គភាពបណ្តាញ នាយកដ្ឋានអាជីវកម្មចែកចាយ នៃអគ្គិសនីកម្ពុជា។

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- សម្រាប់ សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ (ខណ្ឌដោះដាក់នាឡិកាស្ទង់) ចំនួន ០១ រូប :

- បេក្ខជនភេទស្រី, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតវប្បធម៌ : ចាប់ពី សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

២- សម្រាប់ សញ្ញាប័ត្រកម្មករជំនាញអគ្គិសនី( ខណ្ឌបណ្តាញLV, ខណ្ឌបណ្តាញMV, ខណ្ឌបន្ទប់ភ្លើង និង ខណ្ឌដោះដាក់នាឡិកាស្ទង់) សរុបចំនួន ១៤ រូប :

- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រកម្មករជំនាញអគ្គិសនី ឡើងទៅ
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

៣- សម្រាប់ សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី( ខណ្ឌបន្ទប់ភ្លើង) ចំនួន ០១ រូប :

- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ ។
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

៤- សម្រាប់ សញ្ញាប័ត្រវិស្វករអេឡិចត្រូនិក (ខណ្ឌបណ្តាញMV និង ខណ្ឌបន្ទប់ភ្លើង) សរុបចំនួន ០៣ រូប :

- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអេឡិចត្រូនិក ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

៥- សម្រាប់ សញ្ញាប័ត្រវិស្វករអគ្គិសនី( ខណ្ឌបន្ទប់ភ្លើង និង ខណ្ឌដោះដាក់នាឡិកាស្ទង់ )សរុបចំនួន ០២ រូប :

- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

៦- សម្រាប់ សញ្ញាប័ត្រវិស្វករអគ្គិសនី ( ខណ្ឌត្រួតពិនិត្យប្រព័ន្ធនាឡិកាស្ទង់ Indirect និង ខណ្ឌគ្រប់គ្រងគំនូសប្លង់បណ្ដាញ ) សរុបចំនួន ០២ រូប :
- បេក្ខជនទាំង ០២ ភេទ, ត្រូវមានអាយុចាប់ពី ១៨ ដល់ ៣៥ឆ្នាំ
- បៀវត្សផ្ដល់ជូន : បៀវត្សរ៍សុទ្ធ E.I.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%
- កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ
- ចំណេះដឹងកុំព្យូទ័រ : ចេះ Auto Cad
- ភាសាអង់គ្លេស : ចេះ អាចប្រើការបាន ជាមធ្យម ។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

- ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៍( ១.០០០ រៀល) ចំនួន ០១ ច្បាប់
- ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ ចំនួន ០១ ច្បាប់
- សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ( ច្បាប់ចម្លងមានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត )ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់កិរិយាមារយាទ ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ)ចំនួន ០១ ច្បាប់
- ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត ចំនួន ០១ ច្បាប់
- តារាងពិន្ទុ ( TRANSCRIPT ) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) ចំនួន ០១ ច្បាប់

*- **ទីកន្លែងទទួលពាក្យ** :សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ
- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្ដាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**
អគ្គនាយករង

ELECTRICITE DU CAMBODGE

អេង_គន្ធា